ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**ទីស្តីការគណៈរដ្ឋមន្ត្រី**
**លេខ :** ៣៦...សជណ.ហខ

ថ្ងៃព្រហស្បតិ៍ ៩កើត ខែ មាឃ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤
រាជធានីភ្នំពេញ ថ្ងៃទី ២១ ខែ មករា ឆ្នាំ២០២១

**ឧបនាយករដ្ឋមន្ត្រីប្រចាំការ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**
**ជម្រាបជូន**

**-ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាប្រធានគណៈកម្មាធិការសកម្មភាពគោលនយោបាយលើកស្ទួយសហគ្រាសធុនតូច និងមធ្យម**
**-ឯកឧត្តមកិត្តិសេដ្ឋាបណ្ឌិត ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍**
**-ឯកឧត្តមទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន**
**-ឯកឧត្តមរដ្ឋមន្ត្រីក្រសួងទេសចរណ៍**
**-ឯកឧត្តមរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**
**-ឯកឧត្តមរដ្ឋមន្ត្រីក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ**
**-ឯកឧត្តមរដ្ឋមន្ត្រីក្រសួងសុខាភិបាល**
**-ឯកឧត្តមរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

**កម្មវត្ថុ៖** ករណីលទ្ធផលកិច្ចប្រជុំគណៈកម្មាធិការគោលនយោបាយលើកស្ទួយសហគ្រាសធុនតូច និងមធ្យម លើកទី២។

**យោង ៖**- លិខិតលេខ៨៦៨៥ សហវ ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០២០ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- លិខិតលេខ០៣៧ សហវ ចុះថ្ងៃទី៦ ខែមករា ឆ្នាំ២០២១ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ចំណារដ៏ខ្ពង់ខ្ពស់បំផុតរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី២៦ ខែតុលា ឆ្នាំ២០២០។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុនិងយោងខាងលើ ទីស្តីការគណៈរដ្ឋមន្ត្រីសូមជម្រាបជូនឯកឧត្តម ជ្រាបថា ករណីលទ្ធផលកិច្ចប្រជុំគណៈកម្មាធិការគោលនយោបាយលើកស្ទួយសហគ្រាសធុនតូច និងមធ្យម (គ.ស.ស.) លើកទី២ រាជរដ្ឋាភិបាលឯកភាពជាគោលការណ៍ ដូចខាងក្រោម៖

១-ត្រូវកំណត់និយមន័យ SMEs ដោយបែងចែកជា ៣ វិស័យ ដូចខាងក្រោម៖

១)- កសិកម្ម

២)- ឧស្សាហកម្ម

៣)- សេវាកម្ម និងពាណិជ្ជកម្ម

វិស័យនីមួយៗ ត្រូវភ្ជាប់នូវលក្ខខណ្ឌតម្រូវ ២ គឺ៖

១)- ចំនួនបុគ្គលិក

២)- ទំហំផលរបរប្រចាំឆ្នាំ ឬ ទំហំទ្រព្យសកម្ម។

សម្រាប់លក្ខខណ្ឌទី២ ក្រសួង ស្ថាប័នពាក់ព័ន្ធអាចប្រើប្រាស់លក្ខខណ្ឌមួយណាក៏បាន ប៉ុន្តែករណីផលរបរប្រចាំឆ្នាំ និងទ្រព្យសកម្មមិនមានសង្គតិភាពក្នុងការកំណត់សហគ្រាសជា SMEs ត្រូវយកលក្ខខណ្ឌដែលមានកម្រិតខ្ពស់ជាងគេ។

ការកំណត់និយមន័យ ត្រូវបែងចែកលម្អិតទៅតាមវិស័យសំខាន់ៗ ដូចខាងក្រោម៖

| វិស័យ | ចំនួនបុគ្គលិក | | និង | ផលរបរប្រចាំឆ្នាំ (ដុល្លារអាមេរិក) | | ឬ | ទ្រព្យសកម្ម | |
|---|---|---|---|---|---|---|---|---|
| | តូច | មធ្យម | | តូច | មធ្យម | | តូច | មធ្យម |
| កសិកម្ម | 5-49 | 50-199 | | 62 250 – 250 000 | 250 001 - 1 000 000 | | 50 000 - 250 000 | 250 001 - 500 000 |
| ឧស្សាហកម្ម | 5-49 | 50-199 | | 62 500 – 400 000 | 400 001 - 2 000 000 | | 50 000 - 500 000 | 500 001 - 1 000 000 |
| សេវាកម្ម និង ពាណិជ្ជកម្ម | 5-49 | 50-99 | | 62 500 - 250 000 | 250 001 - 1 500 000 | | 50 000 - 250 000 | 250 001 - 500 000 |
| *លក្ខខណ្ឌផលរបរ ឬទ្រព្យសកម្ម ត្រូវកំណត់យកលក្ខខណ្ឌមួយណាដែលមានកម្រិតខ្ពស់ជាងគេ។ | | | | | | | | |

២-(ក)-ការលុបបំបាត់ការផ្តល់អាជ្ញាបណ្ណ ឬ លិខិតអនុញ្ញាតអាជីវកម្ម លិខិតបញ្ជាក់គុណភាព ឬ លិខិតអនុញ្ញាតដែលត្រួតគ្នារវាងក្រសួង ស្ថាប័ន

១)-អំពីធុរកិច្ចក្នុងវិស័យឧស្សាហកម្មទេសចរណ៍

- ក្រសួងទេសចរណ៍ និងក្រសួងសាធារណការនិងដឹកជញ្ជូនត្រូវរៀបចំបទប្បញ្ញត្តិអន្តរក្រសួង ដើម្បីផ្ទេរសមត្ថកិច្ចជូនក្រសួងសាធារណការនិងដឹកជញ្ជូន ដែលជាស្ថាប័នតែមួយក្នុងការផ្តល់អាជ្ញាបណ្ណដឹកជញ្ជូនភ្ញៀវទេសចរ។ អាជ្ញាបណ្ណដឹកជញ្ជូនទំនិញនិងអ្នកដំណើរ ដែលផ្តល់ដោយក្រសួងសាធារណការនិងដឹកជញ្ជូនគឺមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ដោយពុំចាំបាច់តម្រូវឱ្យមានការស្នើសុំអាជ្ញាបណ្ណពីក្រសួងទេសចរណ៍ថែមទៀតនោះទេ

- ក្រសួងទេសចរណ៍ និងក្រសួងសុខាភិបាលត្រូវដាក់បញ្ចូលការផ្តល់អាជ្ញាបណ្ណអាជីវកម្មភោជនីយដ្ឋាន និងវិញ្ញាបនបត្របញ្ជាក់អនាម័យភោជនីយដ្ឋាន និងអាហារដ្ឋាន ទៅក្នុងថ្នាលអនឡាញ CamDX ។ ខណៈការធ្វើអធិការកិច្ចត្រូវអនុវត្តរួមគ្នានិងតែមួយលើកដូចការអនុវត្តក្នុងវិស័យផ្សេងទៀត

- ក្រសួងទេសចរណ៍ត្រូវសម្រួលការផ្តល់អាជ្ញាបណ្ណទេសចរណ៍ច្រើនប្រភេទចំពោះបុគ្គលស្នើសុំតែម្នាក់ចេញពីទីតាំងតែមួយតាមរយៈថ្នាលអនឡាញ CamDX

- ក្រសួងទេសចរណ៍ត្រូវធ្វើវិសោធនកម្មច្បាប់និងបទប្បញ្ញត្តិពាក់ព័ន្ធដើម្បីកែសម្រួលប្រព័ន្ធចំណាត់ថ្នាក់ធុរកិច្ចទេសចរណ៍ដែលជា SMEs ពីលក្ខខណ្ឌតម្រូវមកជាលក្ខខណ្ឌស្ម័គ្រចិត្ត។

**២)-អំពីធុរកិច្ចម្ហូបអាហារកែច្នៃ និងទីផ្សារ**

- ក្រសួងសុខាភិបាលត្រូវលុបចោលការផ្តល់វិញ្ញាបនបត្របញ្ជាក់ការដាក់លក់ផលិតផលចំណីអាហារ និងវិញ្ញាបនបត្របញ្ជាក់អនាម័យផលិតផលចំណីអាហារ លើកលែងចំពោះផលិតផលឱសថ អាហារបំប៉ន និងគ្រឿងសម្អាង ព្រមទាំងផ្ទេរសមត្ថកិច្ចនៃការផ្តល់វិញ្ញាបនបត្របញ្ជាក់អនាម័យ ផលិតផលចំណីអាហារ ជូនក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ដែលមានសមត្ថភាពនិងមន្ទីរពិសោធន៍គ្រប់គ្រាន់លើការត្រួតពិនិត្យអនាម័យ គុណភាព និងសុវត្ថិភាពម្ហូបអាហារកែច្នៃ។ ការផ្តល់វិញ្ញាបនបត្របញ្ជាក់អនាម័យចំពោះផលិតផលចំណីអាហារដែលបានផលិតនិងចែកចាយក្នុងស្រុកនិងសម្រាប់ការនាំចេញ ត្រូវធ្វើឡើងដោយគោលការណ៍ស្ម័គ្រចិត្ត។ ចំណែកផលិតផលនាំចូល ការផ្តល់វិញ្ញាបនបត្របញ្ជាក់អនាម័យផលិតផលចំណីអាហារ ត្រូវអនុវត្តចំពោះផលិតផលដែលមានហានិភ័យខ្ពស់ប៉ុណ្ណោះ

- ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ត្រូវពង្រឹងនិងពន្លឿនយន្តការរដ្ឋបាលក្នុងការផ្តល់អាជ្ញាបណ្ណសម្រាប់ចុះបញ្ជីផលិតផល (ច.ប.ផ.) ដល់ SMEs

- ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ត្រូវកែសម្រួលយន្តការផ្តល់ប្រកាសបង្កើតសហគ្រាសសិប្បកម្មនិងវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ-សិប្បកម្មដោយដាក់បញ្ចូលទៅក្នុងប្រព័ន្ធថ្នាលចុះបញ្ជីអនឡាញ CamDX ដើម្បីឱ្យកាន់តែប្រសើរឡើងនូវការផ្តល់សេវាបានឆាប់រហ័សជូន SMEs។

**២-(ខ)-ការកែសម្រួលការចុះធ្វើអធិការកិច្ច និងការចុះត្រួតពិនិត្យរបស់ក្រសួង ស្ថាប័នពាក់ព័ន្ធ**

**១)-អំពីអធិការកិច្ចជាប្រចាំ**

- ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ត្រូវដឹកនាំនិងសម្របសម្រួលក្រសួង ស្ថាប័នពាក់ព័ន្ធដើម្បីកែសម្រួលប្រកាសអន្តរក្រសួងស្តីពីការបង្កើតក្រុមអធិការកិច្ចអន្តរក្រសួងក្នុងវិស័យឧស្សាហកម្មទេសចរណ៍ដោយបន្ថែមសមាសភាពពីក្រសួងសុខាភិបាលទៅក្នុងក្រុមអធិការកិច្ចអន្តរក្រសួង

-ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ត្រូវដឹកនាំនិងសម្របសម្រួលជាមួយនឹងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រសួងបរិស្ថាន និងក្រសួង ស្ថាប័នពាក់ព័ន្ធ ដើម្បីរៀបចំប្រកាសអន្តរក្រសួងស្តីពីការបង្កើតក្រុមអធិការកិច្ចអន្តរក្រសួងក្នុងវិស័យកសិកម្ម។

**២)-អំពីអធិការកិច្ចពេលមានបញ្ហា ឬ តាមពាក្យបណ្តឹង**

ចំពោះករណីការចុះធ្វើអធិការកិច្ចពេលមានបញ្ហាឬតាមពាក្យបណ្តឹង រាជរដ្ឋាភិបាលសម្រេចបែងចែកការទទួលខុសត្រូវតាមប្រភេទផលិតផល និងទីតាំង ដូចខាងក្រោម៖

- ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ត្រូវផ្តោតលើម្ហូបអាហារ និងផលិតផលនៅទីកន្លែងផលិតកម្ម

- ក្រសួងសុខាភិបាល ត្រូវផ្តោតលើផលិតផលឱសថ អាហារបំប៉នសុខភាព និងគ្រឿងសម្អាងនៅកន្លែងផលិតកម្ម និងទីផ្សារ ព្រមទាំងអនាម័យនៅកន្លែងប្រើប្រាស់ចុងក្រោយ (ភោជនីយដ្ឋាន)

- ក្រសួងពាណិជ្ជកម្ម ត្រូវផ្តោតលើផលិតផលម្ហូបអាហារដែលដាក់លក់នៅលើទីផ្សារ

- គណៈកម្មាធិការប្រយុទ្ធប្រឆាំងផលិតផលក្លែងក្លាយត្រូវសហការជាមួយនគរបាលប្រឆាំងបទល្មើសសេដ្ឋកិច្ចផ្តោតលើផលិតផលក្លែងម៉ាកសញ្ញានៅលើទីផ្សារ និងទីកន្លែងផលិតកម្មដែលត្រូវដឹកនាំដោយក្រសួង ស្ថាប័នមានសមត្ថកិច្ចខាងលើនៅពេលចុះធ្វើអធិការកិច្ច

- ករណីក្រសួង ស្ថាប័នចុះអធិការកិច្ចពេលមានបញ្ហា ឬ បណ្តឹង នៅទីតាំងស្ថិតក្រៅដែនសមត្ថកិច្ចរបស់ខ្លួន ក្រសួង ស្ថាប័ននោះត្រូវជូនដំណឹង និងសហការជាមួយក្រសួង ស្ថាប័នមានសមត្ថកិច្ច។

ដើម្បីលើកកម្ពស់ប្រសិទ្ធភាពនៃការចុះធ្វើអធិការកិច្ចប្រកបដោយតម្លាភាពនិងការពារសិទ្ធិរបស់ SMEs និងសម្របសម្រួលយន្តការគ្រប់គ្រងការតាមដាននិងវាយតម្លៃវិធានការលើកស្ទួយ SMEs រាជរដ្ឋាភិបាលសម្រេចជាគោលការណ៍លើវិធានការបំពេញបន្ថែមមួយចំនួន ដូចខាងក្រោម៖

១)-ជំរុញឱ្យមន្ត្រីអនុវត្តច្បាប់បញ្ជាក់ជូនម្ចាស់សហគ្រាសបានដឹងពីសិទ្ធិស្របច្បាប់របស់ម្ចាស់សហគ្រាស, សិទ្ធិក្នុងការប្រើប្រាស់សេវាមេធាវីនិងសិទ្ធិដទៃទៀត និងករណីការចុះអធិការកិច្ចដែលមិនអនុវត្តត្រឹមត្រូវតាមនីតិវិធី, លទ្ធផលនៃការត្រួតពិនិត្យត្រូវចាត់ទុកជាមោឃៈដោយអគ្គប្រយោជន៍ផ្នែកច្បាប់ត្រូវផ្តល់ជូនម្ចាស់សហគ្រាស។

២)-លើកទឹកចិត្តការប្រើប្រាស់យន្តការទន់ភ្លន់ក្នុងការចុះអធិការកិច្ចដោយការអប់រំនិងណែនាំដល់ម្ចាស់សហគ្រាស មុននឹងឈានដល់ការប្រើប្រាស់នូវយន្តការតុលាការ។

៣)-បង្កើតក្រុមការងារបច្ចេកទេសអន្តរក្រសួង ស្ថាប័នតាមដាន និងវាយតម្លៃសកម្មភាពគោលនយោបាយលើកស្ទួយសហគ្រាសធុនតូច និងមធ្យម។

អាស្រ័យដូចបានជម្រាបជូនខាងលើសូមឯកឧត្តមជ្រាបនិងចាត់ចែងអនុវត្ត។

**ឧ.រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**
**រដ្ឋលេខាធិការប្រចាំការ**

បណ្ឌិតសភាចារ្យ **ហ៊ីង ថូរ៉ាក់ស៊ី**

**ចម្លងជូន៖**
-ក្រសួងមហាផ្ទៃ
-ក្រសួងបរិស្ថាន
-ក្រសួងព័ត៌មាន
-ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
-ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត ឧបនាយករដ្ឋមន្ត្រីប្រចាំការ
-គណៈកម្មាធិការប្រយុទ្ធប្រឆាំងផលិតផលក្លែងក្លាយ
-ឯកសារ កាលប្បវត្តិ